ភ្នំពេញ ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ១៩៩៣

**គោរពជូនមក**

លោកនាយកផ្នែកវិទ្យុផ្សាយសម្លេងអ៊ុន តាក់

<u>កម្មវត្ថុ</u>៖ សូមមេត្តាផ្សាយសម្លងនូវបទកំណាព្យពាក្យប្រាំពីរដែលមានចំណងជើងថា "សិទ្ធិមានត្រឹមណា" ដោយអនុគ្រោះ។

ហត្ថលេខា

សេង យាន

## <u>សិទ្ធិមានត្រឹមណា</u>

ឱសិទ្ធិសេរីថ្លៃម្ល៉េះទេ ទាំងខ្ញុំទាំងគេចង់បានណាស់
មានសិទ្ធិសេរីកើតប្រាជ្ញាច្បាស់ ហ៊ានថាហ៊ានដាស់សតិផងគ្នា។

សិទ្ធិសេរីជាអាវុធពិសិដ្ឋ បើចេះប្រើពិតទើបល្អជា
តែចេះស្ទើរៗអាចក្លាយជា អាវុធប្រហារគ្មានរើសមុខ។

ឱបងប្អូនអើយសូមជួយគិត ខ្ញុំរំលឹកគំនិតមកដាក់ទុក
ព្រោះចង់ឲ្យខ្មែរយើងបានសុខ ពេលសិទ្ធិពេញស្រុកត្រូវចេះប្រើ។

ប្រើសិទ្ធិបានល្អរួចផុតទុក្ខ បងប្អូនអ្នកស្រុកកោតសរសើរ
ស្រឡាញ់រាប់រករួមដំណើរ រាក់ទាក់ឈានដើរមិនមានភ័យ។

ចេះប្រើសិទ្ធិឥតរំលោភគេ ព្រោះយល់សិទ្ធិគេជាមនុស្សថ្លៃ

មនុស្សដូចគ្នាទេចរណែ		ត្រូវចេះលកលែយល់គេឯង។

សិទ្ធិប្រើសម្លេងហោរសប្បាយ		រីករាយក្អាកក្អាយលាន់បែកផ្សែង
តែសុំគិតផងណាព្រះស្តែង		ត្រូវចេះរអែងអ្នកជិតខាង។

ស្រែកហោរមានពេលម៉ោងកំណត់		កុំក្បត់យកសិទ្ធិខ្លួនមកអាង
សិទ្ធិគេមានដែរកុំប្រងាង		នាំគ្នាសាងសុខទើបប្រពៃ។

សិទ្ធិចាក់មេក្រូឮលាន់មេឃ		បានលុយឥតខ្លាចពីណាក្សយ័
ខំបើកឲ្យឮអួតទិញថ្លៃ		ម្ចាស់ថោកចង្រៃមិនស្គាល់សិទ្ធិ។

រឿងនេះម្ចាស់បុណ្យម្ចាស់មេក្រូ		គួរតែគិតគូរឲ្យបានល្អិត
ពេលណាគួរឮពេលណាបិទ		ឲ្យឮល្មមពិតផុតគេដេរ។
សិទ្ធិប្រើផ្លូវថ្នល់សាធារណៈ		ត្រូវចេះច្បាប់ដាក់កុំធ្វេសទ្វេ
គ្មានប័ណ្ណបើកបរប្រថុយដែរ		កើតទុក្ខឥតល្ហែពេលគ្រោះថ្នាក់។

ទុក្ខមួយព្រួយកាយឈឺខ្លោចផ្សា		អាចក្លាយពិការដល់មរណៈ
ទុក្ខមួយព្រួយព្រោះបង់ទ្រព្យប្រាក់		ក្តុកក្តួលអួលអាក់ធ្លាក់ក្របាន។

អ្នកដើរអ្នកជិះកង់ម៉ូតូ		អ្នកជាក់ស៊ីក្លូអ្នកបើកឡាន

សិទ្ធិខ្លួនត្រឹមណាកុំក្លាហាន		ក្រែងធាប់ចាកឋានខានសប្បាយ។

សិទ្ធិចិញ្ចឹមសត្វប្រាថ្នាសាច់		មាន់ជ្រូកគោអាចម៍ឈ្នួសកកាយ
ស៊ីដំណាំផងហិនគួរស្តាយ		បែរហ៊ានមាក់ងាយបន្ទោសថា។

ម្តេចមិនដេញផងសត្វដឹងអ្វី		ចំជាអប្រិយ៍ពោលមុសា
ខ្លួនខុសជ្រងោបែរតវ៉ា		ស្តីថារំលោភសិទ្ធិគេផង។

សត្វមិនចេះដឹងសិទ្ធិអ្វីទេ		ប៉ុន្តែម្ចាស់មេកុំរំលង
រំលោភគេពេកនាំសោះហ្មង		គេដាំប៉ុនប៉ងបានផល្លា។

ប្រយោជន៍ចង់បានរៀងៗខ្លួន		ប៉ុន្តែម្ចាស់ស្ងួនត្រូវយល់គ្នា
ត្រូវស្គាល់ព្រំដែនសិទ្ធិត្រឹមណា		កុំចេះតែថាឥតមានខ្មាស់។

សិទ្ធិចូលធ្វើការបំរើជាតិ		តែកុំប្រើស្មៀតបែបផ្តេសផ្តាស
លោភលន់កេងកិបធាប់រហ័ស		ស្តារដើមក្រែលក្រាសឲ្យជាតិក្រ។

សិទ្ធិនេះមិនល្អទេណាថ្លៃ		ចង់មានទាំងថ្ងៃម្នុសកុះករ
គេចាំតែមើលកុំវីវរ		តែហ៊ានលបលលង់ពុំខាន។

សិទ្ធិចូលសាងផ្នួសសាងសីលទាន　　កើតបានជាស្ថានឆ្លងទៅឋាន
សួគ៌សុខគ្មានទុក្ខហៅនិព្វាន　　សិទ្ធិចេះព្រានលានកោតគោរព។
សិទ្ធិកាប់គាស់ដីស្រែចំការ　　បង្កើតផល្លាចិញ្ចឹមគ្រប់
មនុស្សម្នាខេត្តក្រុងអរចំប្រប់　　លើកម្រាមដៃដប់សូមជូនពរ។

សិទ្ធិឈ្មួញជួញប្រែតាមទីផ្សារ　　លក់ដូរភ័ស្តុភារហុរហៀរគរ
ចិត្តមិនសូវល្អច្រើនភូតភរ　　ល្មមអាជ្ញាធរមើលគាត់ផង។

កុំបើកសិទ្ធិកាត់ហួសព្រំដែន　　ព្រោះតែសូកសែនហ៊ានកន្លង
រង្វាស់វាល់ថ្លឹងខុសទំនង　　សិទ្ធិនេះប្អូនបងឆាប់ទប់ទល់។

សិទ្ធិបែបរកស៊ីមិនមានដើម　　ឆក់ប្លន់សំបើមឥតគិតខ្វល់
បាញ់កាប់សម្លាប់ឥតយោគយល់　　ហួសព្រំប្រទល់សិទ្ធិហើយថ្លៃ។

អ្វីទៅសិទ្ធិអ្នកអាចធ្វើបាន　　ត្រង់កុំបំពានអ្នកដទៃ
ឲ្យគេកើតទុក្ខឈឺផ្សាក្រៃ　　សិទ្ធិនេះមានថ្លៃជាប់ចំណាង។

សិទ្ធិសារព័ត៌មានហ៊ានសរសេរ　　អស់ពួកវាចរេស្អប់កន្លង
គ្មានលាក់គ្មានបាំងយោគយល់ផង　　រាស្ត្រអរកន្លងមានសិទ្ធិនេះ។

សិទ្ធិចេះជួយជាភ្នែកប្រមុះ      រាំងស្កាត់កំហុសពួកពុកច្រេះ
ជួយផ្តល់យោបល់សាងប្រទេស      សិទ្ធិចេះល្អម្លេះសូមសុខសាន្ត។
សិទ្ធិមនុស្សច្រើនណាស់រាប់មិនអស់      ខ្ញុំលើកចោះៗតាមលំអាន
ខុសឆ្គងម្តេចម្ចាសូមសន្តាន      មេត្តាប្រោសប្រាណខ្លួនខ្ញុំផង។